# តារាងសង្ខេបអំពីភាពពាក្យកិច្ចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

## (ក្នុងស្រុក -បរទេស)

## ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

| **ភាពពាក្យកិច្ច** | **ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត (មាត្រា/លេខ)** | **ឯកសារយោងនិងភាពបរិច្ឆេទ** |
| --- | --- | --- |
| **សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** | | |
| សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ | មាត្រា៦ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ | មាត្រា៩ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| **ការបង្កើត និងចុះបញ្ជី**<br>១.ការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (សម្រាប់រូបវន្តបុគ្គល) | មាត្រា៥ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការ |

| | | |
|---|---|---|
| ក.<u>លក្ខខណ្ឌ នៃការបង្កើត</u><br>ក.១.<u>ការបង្កើតសមាគម</u><br>– តម្រូវឲ្យមានសមាជិកស្ថាបនិក ជារូបវន្តបុគ្គលចំនួន៣រូបយ៉ាងតិច<br>– អាយុគ្រប់១៨ឆ្នាំឡើងទៅ។<br>ក.២.<u>ការបង្កើតអង្គការមិនមែនរដ្ឋាភិបាល</u><br>– តម្រូវឲ្យមានសមាជិកស្ថាបនិកជារូបវន្តបុគ្គល (សញ្ជាតិខ្មែរ) ចំនួន៣ រូបយ៉ាងតិច<br>– អាយុគ្រប់១៨ឆ្នាំឡើងទៅ។<br><br>ខ.លក្ខខណ្ឌ នៃការចុះបញ្ជី ត្រូវរៀបចំនូវសំណុំលិខិតដូចខាងក្រោម៖<br>– ពាក្យសុំចុះបញ្ជី<br>– លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការកណ្តាល (បញ្ជាក់ពីមេឃុំ ឬ ចៅសង្កាត់)<br>– ជីវប្រវត្តិស្ថាបនិក<br>– លក្ខន្តិកៈចុះហត្ថលេខាដោយប្រធាន។<br>គ.<u>នីតិវិធី នៃការចុះបញ្ជី</u><br>– ក្រសួងមហាផ្ទៃព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីក្នុងរយៈពេល យ៉ាងយូរ ៤៥ ថ្ងៃ នៃថ្ងៃធ្វើការ<br>– កម្រៃសេវារដ្ឋបាលចុះបញ្ជី ចំនួន ៣០០.០០០រៀល មានសុពលភាព អចិន្ត្រៃយ៍។<br>– (ប្រកាសអន្តរក្រសួងលេខ១៤៨១៤ ប្រក ចុះថ្ងៃ៣០ ខែធ្នូ ឆ្នាំ២០១៦ របស់ MOI និង MEF) | **មាត្រា៦**<br><br>**មាត្រា ៨** | <u>តាមព្រះរាជក្រមលេខ នស/រកម/០៨១៥/ ០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥</u> |

| | | |
|---|---|---|
| ២.<u>ការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក</u> (សម្រាប់នីតិបុគ្គល)<br>អនុលោមតាមមាត្រា១១ ក្រសួងមហាផ្ទៃបានសម្រេចដាក់ចេញប្រកាសលេខ២១៩៣ ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល។<br><br>តាមស្មារតីប្រកាសនេះ បានកំណត់ដូចខាងក្រោម៖<br><br>**ក.ការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល (ប្រការ៤)**<br>– សមាជិកស្ថាបនិក ជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬនីតិបុគ្គល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ពាក់ព័ន្ធជាធរមាន<br>– យ៉ាងហោចចំនួន៣ឡើងទៅ<br>– ត្រូវមានប្រធាន១រូប ឬតំណាងស្ថាបនិក១រូប សម្រាប់រៀបចំបែបបទស្នើសុំចុះបញ្ជី<br>**ខ.ការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល (ប្រការ៥)**<br>ត្រូវរៀបចំនូវសំណុំលិខិតដូចខាងក្រោម៖<br>– ពាក្យសុំចុះបញ្ជី<br>– ប្រកាស ឬឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជាសមាជិក ឬនីតិបុគ្គលផ្សេងទៀត<br>– លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការកណ្តាល (បញ្ជាក់ពីមេឃុំ ឬចៅសង្កាត់)<br>– ជីវប្រវត្តិប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬនីតិបុគ្គលដែលជាស្ថាបនិក<br>– លក្ខន្តិកៈចុះហត្ថលេខាដោយប្រធាន។ | មាត្រា១១ និងប្រកាសលេខ២១៩៣ | <u>ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥</u><br><br><u>ប្រកាសលេខ២១៩៣ ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល។</u> |

| | | |
| --- | --- | --- |
| **លក្ខន្តិកៈសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់រូបវន្តបុគ្គល និងសម្រាប់នីតិបុគ្គល**<br><br>លក្ខន្តិកៈសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់រូបវន្តបុគ្គល និងសម្រាប់នីតិបុគ្គល ត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់នានាជាធរមាន និងត្រូវមានចំណុចសំខាន់ៗ ដូចខាងក្រោម៖<br>– គោលបំណង និងគោលដៅ<br>– ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនចម្លងតាមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ<br>– សញ្ញាសម្គាល់មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ ឬសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិ<br>– វិធានការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ<br>– វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ<br>– ប្រភពធនធាន និងទ្រព្យសម្បត្តិ<br>– វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ<br>– វិធាននៃការរំលាយ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ។ | មាត្រា៧ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| **បន្ទាប់ពីចុះបញ្ជីស្របតាមច្បាប់ ត្រូវបំពេញភារកិច្ច ដូចខាងក្រោម៖**<br>– ត្រូវធ្វើសកម្មភាពឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងលក្ខន្តិកៈរបស់ខ្លួន<br>– ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី<br>– ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធានឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ។<br>– អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវមានជំហរអព្យាក្រឹត្យចំពោះគ្រប់គណបក្សនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>– អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។<br>– ករណីទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ ត្រូវផ្ញើរបាយការណ៍នេះ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល៣០ ថ្ងៃ គិតចាប់ថ្ងៃផ្ញើទៅម្ចាស់ជំនួយ។ | មាត្រា ១០,២៤,២៥ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| **ការផ្អាកសកម្មភាព ការរំលាយ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ**<br>ក.ការផ្អាកសកម្មភាព និងការរំលាយ<br>– អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។<br>– មុននឹងផ្អាកសកម្មភាព ត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុង កថាខណ្ឌទី ១ នៃមាត្រា ២៥ នៃច្បាប់នេះ ។<br>– មុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទបញ្ញាតិជាធរមាន ។<br>ខ.ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ<br>– ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមលក្ខន្តិកៈរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។<br>– រំលាយ ដោយសេចក្តី សម្រេចរបស់តុលាការ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ការជម្រះកាតព្វកិច្ច ព្រមទាំងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។ | មាត្រា២៦,២៨,២៩ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| **ទទួលបាននូវសិទ្ធិ និងផលប្រយោជន៍**<br><br>**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីស្របតាមច្បាប់ ទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ ដូចខាងក្រោម៖** | មាត្រា២០,២១,២២ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| – ទទួលបាននូវសិទ្ធិជានីតិបុគ្គលចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី<br>– ត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ និងបទប្បបញ្ញត្តិជាធរមាន<br>– ទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បបញ្ញត្តិជាធរមាន<br>– មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោង<br>– មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករដើម្បីបំរើការងារស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។ | | |
| **វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ**<br><br>**ករណីមិនបានអនុវត្តស្របតាមច្បាប់នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នឹងប្រឈមទៅនឹង វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ៖**<br><br>– សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។<br>– អាជ្ញាធរត្រូវបញ្ឈប់ជាបន្ទាន់ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី។ ក្នុងករណីមិនរាងចាល ត្រូវពិន័យពី ០៥ ទៅ ១០ លានរៀល ដោយក្រសួងមហាផ្ទៃ។ ក្នុងករណីបន្តសកម្មភាពទៀត អាជ្ញាធរត្រូវប្តឹងទៅតុលាការដើម្បីចាត់វិធានការតាមច្បាប់ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌ។ | មាត្រា៩ ,៣០,៣២ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| – ក្រសួងមហាផ្ទៃ ត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជី ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ប្រពៃណី ទំនៀមទំលាប់ល្អរបស់សង្គមជាតិ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌផ្សេងទៀត។<br>– ករណីមិនអនុវត្តតាមបញ្ញត្តិមាត្រា១០ មាត្រា២៤ ឬកថាខណ្ឌទី១ និងទី២ នៃមាត្រា២៥ (កថាខណ្ឌទី១ នៃមាត្រា៣០)<br>– ករណីមិនអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈ (កថាខណ្ឌទី២ នៃមាត្រា៣០) | | |
| **សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស** | | |
| សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការ ក្រោមទម្រង់ជាការចុះអនុស្សរណៈ។ | **មាត្រា១២** | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការ មិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ | **មាត្រា៣៤** | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| **ការបង្កើត និងចុះបញ្ជី**<br>១.<u>ការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស</u><br><u>ក.លក្ខខណ្ឌ នៃការចុះបញ្ជី ត្រូវរៀបចំនូវសំណុំលិខិតដូចខាងក្រោម៖</u><br>– លិខិតរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានទីស្នាក់ការ អចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំង | មាត្រា១៣ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| តំណាងរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេប របស់បុគ្គលដែលស្នើតែងតាំងចំនួន ១ (មួយ) ច្បាប់ និងស្នើបើកទីស្នាក់ការតំណាងចំនួន ១ (មួយ)ច្បាប់<br>– លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ ឬចៅសង្កាត់ចំនួន ១ (មួយ) ច្បាប់<br>– លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើម អនុញ្ញាតឲ្យសមាគម ឬអង្គការ មិនមែនរដ្ឋាភិបាលបរទេសដំណើរការចំនួន ១ (មួយ) ច្បាប់<br>– លិខិតគាំទ្រគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយ អាជ្ញាធរសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់<br>– លិខិតបញ្ជាក់ពីចំនួនថវិកាសម្រាប់អនុវត្តគម្រោងនានារបស់សមាគម ឬអង្គការមិនមែន រដ្ឋាភិបាលបរទេស រយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍ខ្លួននៅ បរទេសចំនួន ១ (មួយ) ច្បាប់<br>– លិខិតសន្យាផ្តល់នូវរាល់គណនីនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅ ធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់ ។ | | |
| <u>ខ.នីតិវិធី នៃការចុះបញ្ជី</u><br>– ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវ សម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស យ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។ | **មាត្រា១៤,១៥,១៦** | |

| | | |
|---|---|---|
| – សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើការពិភាក្សាឯកភាពជាមួយអាជ្ញាធរ សាធារណៈដែលជាដៃគូលើគម្រោងនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងចំណុចទី ៤ នៃមាត្រា ១៣ នៃច្បាប់នេះ ។<br>គ.សុពលភាពអនុស្សរណៈ<br>– អនុស្សរណៈមានសុពលភាពរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ ដោយផ្អែកតាមគម្រោងនានារបស់ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។<br>– សុពលភាពអនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់ ។<br>– ក្នុងករណីមានបំណងបន្តសុពលភាព អនុស្សរណៈ ត្រូវដាក់ពាក្យសុំបន្តសុពលភាពអនុស្សរណៈឲ្យបាន ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ ។ | | |
| **បន្ទាប់ពីចុះបញ្ជីស្របតាមច្បាប់ ត្រូវបំពេញភាតព្វកិច្ច ដូចខាងក្រោម៖**<br>– ត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។ | មាត្រា១៧ ,២៤,២៥ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការ តាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| – ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីមានការផ្លាស់ប្តូរ ទីស្នាក់ការ តំណាង ឬតំណាងប្រចាំប្រទេស ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាង យូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដែលបានផ្លាស់ប្តូរ ។ | | |
| **ការផ្អាកសកម្មភាព ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ**<br>**<u>ក.ការផ្អាកសកម្មភាព និងការបញ្ចប់សុពលភាពអនុស្សរណៈ</u>**<br>– អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការ ។<br>– មុននឹងផ្អាកសកម្មភាព ត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុង កថាខណ្ឌទី ៣ នៃមាត្រា ២៥ នៃច្បាប់នេះ ។<br>– មុននឹងបញ្ចប់សុពលភាពអនុស្សរណៈត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទបញ្ញាតិជាធរមាន ។<br>**<u>ខ.ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ</u>**<br>– ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមអនុស្សរណៈ ឬកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ។<br>– ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលត្រូវបានក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សម្រេចបញ្ចប់សុពលភាពអនុស្សរណៈមុនកាលកំណត់ ការចាត់ចែងធនធាន និង | មាត្រា២៧,២៨,២៩ | <u>ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥</u> |

| | | |
|---|---|---|
| ទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា ។ | | |
| **ទទួលបាននូវសិទ្ធិ និងផលប្រយោជន៍**<br><br>**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះបញ្ជីស្របតាមច្បាប់ ទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ ដូចខាងក្រោម៖**<br>– ទទួលបាននូវសិទ្ធិជានីតិបុគ្គលចាប់ពីថ្ងៃដែលបានចុះបញ្ជី<br>– ត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងបទប្បបញ្ញត្តិជាធរមាន<br>– ទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បបញ្ញត្តិជាធរមាន<br>– មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោង<br>– មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករដើម្បីបំរើការងារស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។ | មាត្រា២០,២១,២២ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |
| **វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ**<br><br>**ករណីមិនបានអនុវត្តស្របតាមច្បាប់នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស នឹងប្រឈមទៅនឹងវិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ៖** | មាត្រា៣៣,៣៤,៣៥,៣៦ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| – ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា ១៧ ឬមាត្រា ២៤ ឬកថាខណ្ឌទី៣ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ ។<br>– ក្នុងករណី មិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយ ទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ។ ក្នុ<br>– ងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាព អនុស្សរណៈ ។<br>– អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។<br>– ការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើ ការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលប្រព្រឹត្តល្មើសខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។<br>– អាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុង ករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈ ដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |

| | | |
|---|---|---|
| – ឬក្នុងករណីដែលសមាគម ឬអង្គការ មិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ<br>– ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ កម្ពុជា ។<br>– សកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃ ព្រះរាជាណាចក្រកម្ពុជា ។ | | |